# បណ្ណព័ត៌មានអំពី
# *ការស្វាគមន៍លើភាពផ្សេងគ្នារបស់ Territory*

*ការស្វាគមន៍លើភាពផ្សេងគ្នារបស់ Territory* គឺជាគោលនយោបាយពហុវប្បធម៌លើកដំបូងរបស់ Northern Territory សំរាប់ប្រជាពលរដ្ឋអន្តោប្រវេសន៍ និង ជាតិពន្ធទាំងឡាយដែលរស់នៅក្នុង Territory ។

គោលនយោបាយនេះកើតមានឡើងនៅបន្ទាប់ពីដំណើរការពិគ្រោះយោបល់យ៉ាងខ្លាំងក្លា ដែលមានរួមទាំង ឯកសារពិភាក្សា, ក្រដាសស្រង់មតិ, ការប្រជុំសាធារណៈ, សិក្ខាសាលា និង ការប្រជុំជាមួយបណ្តាក្រុមនិងមេដឹកនាំសហគមន៍។

នៅពាសពេញ Territory ប្រជាពលរដ្ឋឲ្យតម្លៃប្រវត្តិសាស្ត្ររបស់យើងដែលសម្បូរដោយភាពផ្សេងគ្នា ខាងផ្នែកវប្បធម៌ និង ភាសា។ ភាពផ្សេងគ្នារបស់យើង បានពង្រឹងភាពរុងរឿងនៃសង្គមយើង - លើវិស័យសេដ្ឋកិច្ច សង្គម វប្បធម៌ និង នយោបាយ។

## ការប្តូរផ្តាច់របស់រដ្ឋាភិបាល ចំពោះពហុវប្បធម៌និយម

ទស្សនៈវិស័យរបស់រដ្ឋាភិបាល Northern Territory គឺសំរាប់សង្គមមួយដែលមាំមួននិងមានទំនុកចិត្ត។ ភាពផ្សេងគ្នានៃវប្បធម៌និងភាសារបស់យើង គឺជាទ្រព្យសម្បត្តិដ៏សំខាន់មួយនៅក្នុងការសំរេចបានទស្សនៈវិស័យនេះ។

ទស្សនៈវិស័យនេះគឺអំពីការមានសង្គមរាប់បញ្ចូលមួយ ដែលពលរដ្ឋទាំងអស់នៅក្នុង Territory មានឱកាសស្មើគ្នា និងការទទួលខុសត្រូវ ដើម្បីរួមវិភាគទានចំពោះជីវិតរបស់ Territory ។ នេះមានន័យថា ប្រព្រឹត្តិអំពើរវាងគ្នាប្រកបដោយសេចក្តីគោរព សេចក្តីថ្លៃថ្នូរ និង ដោយគ្មានការប្រកាន់រើសអើង។

រដ្ឋាភិបាលអះអាងបញ្ជាក់ការប្តូរផ្តាច់របស់ខ្លួនចំពោះពហុវប្បធម៌និយម - សង្គមពហុវប្បធម៌ដែលឲ្យតម្លៃភាពផ្សេងគ្នា និងលើកកំពស់ភាពស្និតរមួតនឹងគ្នា សាមគ្គីភាព និង ការចែកចាយគ្នានូវវប្បធម៌រៀងខ្លួន។

## គោលការណ៍

*ការស្វាគមន៍លើភាពផ្សេងគ្នារបស់ Territory* បង្កើតគោលការណ៍ដែលនឹងណែនាំឆ្ពោះទៅកាន់ការបង្កើតគោលនយោបាយនិងកម្មវិធីទាំងឡាយ ដែលពង្រឹងភាពផ្សេងគ្នារបស់ Territory ។

*គោលការណ៍ទី 1: ឲ្យតម្លៃភាពផ្សេងគ្នា*
ធនធាននិងជំនាញការវប្បធម៌និងភាសារបស់ពលរដ្ឋនៃ Territory ត្រូវបានគេឲ្យតម្លៃជាទ្រព្យសម្បត្តិសង្គមនិងសេដ្ឋកិច្ច ហើយត្រូវបានគេទទួលស្គាល់ចំពោះផលប្រយោជន៍ដ៏ធំ ដែលបង្កដោយភាពផ្សេងគ្នា ចំពោះ Territory ទាំងមូល។

*គោលការណ៍ទី 2: ការទទួលបានដោយត្រឹមត្រូវ*
ពលរដ្ឋទាំងអស់នៅក្នុង Territory ដោយពុំគិតអំពីសាវតារដើមរបស់អ្នកទាំងនោះ មានសិទ្ធិទទួលដោយត្រឹមត្រូវនិងស្មើភាពនូវកិច្ចបំរើ(សេវា)និងកម្មវិធីទាំងឡាយរបស់រដ្ឋាភិបាល នៅក្នុងពេលទទួលស្គាល់សេចក្តីត្រូវការខុសៗគ្នាដែលកើតចេញពីភាពផ្សេងគ្នានៃវប្បធម៌និងភាសារបស់ពលរដ្ឋក្នុង Territory ។

*គោលការណ៍ទី 3: ជំរុញទឹកចិត្តឲ្យមានការចូលរួម*
ពលរដ្ឋទាំងអស់នៅក្នុង Territory មានសិទ្ធិ ការទទួលខុសត្រូវ និង ឱកាសដូចគ្នា ដើម្បីចូលរួមដោយពេញលេញនៅក្នុងការអភិវឌ្ឍរបស់ Territory ។

*គោលការណ៍ទី 4: ការគោរពគ្នាទៅវិញទៅមក*
វប្បធម៌ ភាសា និង សាសនារបស់ពលរដ្ឋនៃ Territory ត្រូវបានគេគោរព ក្នុងរង្វង់ក្របខ័ណ្ឌឱបក្រសោបនៃច្បាប់អូស្ត្រាលី និង Northern Territory ហើយនិងស្ថាប័នសង្គម នយោបាយ និង ច្បាប់របស់យើង។

## ការដាក់គោលនយោបាយឲ្យទៅជាការប្រតិបត្តិ

*ការស្គាល់បនាលើភាពផ្សេងគ្នារបស់ Territory* គឺជាឯកសារ"មានជីវិត"មួយ ដែលអាចឆ្លុះបញ្ចាំងសេចក្តីត្រូវការ អាទិភាព និង ការត្រូវប្រឹងប្រែងដែលមានការផ្លាស់ប្តូរ។ គោលនយោបាយនេះមានរួមទាំងយន្តការផ្សេងៗមួយចំនួន ដើម្បីដាក់គោលនយោបាយនេះទៅក្នុងការអនុវត្ត:

### *ការចូលរួមរបស់សហគមន៍:*

អង្គភាពទាំងពួងរបស់រដ្ឋាភិបាលនឹងប្រតិបត្តិការអនុវត្ត"ការចូលរួមដោយសហគមន៍"។ នេះមានន័យថា ស្វែងរកវិធីប្រសើរឡើងដើម្បីធ្វើការជាមួយបុគ្គល អង្គការ និង អ្នករួមផលចំណែក ដែលតំណាងឲ្យពលរដ្ឋអន្តោប្រវេសន៍ និងជាតិពន្ធទាំងពួងនៅក្នុង Territory ។ ការបារម្ភគឺអំពីសេចក្តីត្រូវការអ្នកមកពីសាវតារវប្បធម៌និងភាសាផ្សេងគ្នា ឬ អ្នកដែលពុំមានភ្ជាប់ទៅនឹងបណ្តាញជំនួយដែលមាននៅគ្រាសព្វថ្ងៃនេះ។

### *ការធ្វើរបាយការណ៍*

រៀងរាល់ឆ្នាំ បណ្តាអង្គភាពរបស់រដ្ឋាភិបាលនឹងរាយការណ៍អំពីការផ្តួចផ្តើមដែលបង្ហាញការរីកចំរើន ដោយប្រៀបធៀបនឹងគោលការណ៍ទាំងឡាយ។ គេនឹងប្រើព័ត៌មាននេះដើម្បីប្រមូលព័ត៌មានមួយសំរាប់ចែកចាយជាសាធារណៈ។ សេចក្តីរាយការណ៍នេះនឹងមានរួមទាំងការផ្តល់ព័ត៌មានចុងក្រោយរបស់អង្គភាព និង សេចក្តីសង្ខេបនៃស្នាដៃ លទ្ធផល និងបញ្ហាដែលលេចចេញឡើងដ៏សំខាន់នានា ដែលប៉ះពាល់ដល់ពលរដ្ឋអន្តោប្រវេសន៍ និងជាតិពន្ធទាំងឡាយ នៅក្នុង Territory ។

### *ក្រុមពិគ្រោះយោបល់*

ក្រុមពិគ្រោះយោបល់សំខាន់ទាំងឡាយនឹងទទួលប្រាក់ឧបត្ថម្ភតទៅទៀត។ បន្ថែមទៅទៀតនោះ គេនឹងបង្កើតក្រុមមួយនៃថ្នាក់ងារជាន់ខ្ពស់។ ក្រុមនេះនឹងធ្វើឲ្យប្រាកដថា មានការគ្រប់គ្រងកាន់តែប្រសើរនៅក្នុងរដ្ឋាភិបាល អំពីបញ្ហានៃភាពផ្សេងគ្នា ហើយនឹងជួយកែលំអការយល់ដឹងនៃបញ្ហាលេចចេញឡើង ដែលប៉ះពាល់ដល់សហគមន៍អន្តោប្រវេសន៍និងជាតិពន្ធ។

### *ការពិនិត្យឡើងវិញ*

គោលនយោបាយនេះនឹងត្រូវពិនិត្យឡើងវិញនៅត្រឹមឆ្នាំ 2009 ដើម្បីធ្វើឲ្យប្រាកដថា គោលនយោបាយនេះបន្តឆ្លុះបញ្ចាំងគំនិត និង សេចក្តីរំពឹងរបស់សហគមន៍នៅគ្រាសព្វថ្ងៃ។ គំរោងពេលវេលានេះអនុញ្ញាតឲ្យរួមបញ្ចូលនូវបញ្ហាទាំងពួងដែលលេចចេញពីការពិភាក្សាអំពីភាពជារដ្ឋ នៅក្នុងដំណើរការនេះ។

### ***ទិន្នន័យ EEO***

រដ្ឋាភិបាល NT គឺជានិយោជកធំបង្អស់តែមួយគត់របស់ Territory ។ នៅក្នុងការកំណត់កំរិតស្តង់ដារនៅក្នុងការគ្រប់គ្រងបញ្ហានៃភាពផ្សេងគ្នា គេនឹងចាត់ឲ្យមានជំហានទាំងឡាយដើម្បីបង្កើតវិធី"អនុវត្តន៍"ល្អបំផុត ដើម្បីកែលំអការប្រមូលផ្តុំទិន្នន័យ"ឱកាសការងារស្មើគ្នា" (EEO) ។ សំណុំឯកសារ EEO មួយរបស់បុគ្គលិកនៃរដ្ឋាភិបាល NT នឹងត្រូវបោះផ្សាយរៀងរាល់ឆ្នាំ។

## ព័ត៌មានបន្ថែម

លោកអ្នកអាចទទួលព័ត៌មានបន្ថែមអំពី*ការស្គាល់បនាលើភាពផ្សេងគ្នារបស់ Territory* ពីការិយាល័យកិច្ចការពហុវប្បធម៌ (Office of Multicultural Affairs [OMA]) ។

OMA គឺជាផ្នែកសំខាន់មួយរបស់នាយកដ្ឋានការចូលរួមរបស់សហគមន៍ (Community Engagement Division) ក្នុងរង្វង់ក្រសួងនៃប្រមុខរដ្ឋមន្ត្រី (Department of the Chief Minister) ។ នេះមានន័យថា បញ្ហាទាំងឡាយដែលប្រឈមមុខដោយពលរដ្ឋអន្តោប្រវេសន៍ និង ជាតិពន្ធនៅក្នុង Territory គឺជាចំណុចស្នូលរបស់សកម្មភាពរដ្ឋាភិបាល លើការចូលរួមរបស់សហគមន៍ និង ដំណើរការបង្កើតគោលនយោបាយ។

*Updated: April 2005*